# បេត្តិវិសយភូមិ និងអសុរភូមិ

រៀបចំដោយ ភិក្ខុវិមលោ **សាន ថាវីន**

សត្វ ឈ្មោះថា **បេត** ប្រេត ព្រោះមានអត្ថថា ប្រាសទៅ គឺប្រាសទៅហើយចាកសេចក្តីសុខដ៏ក្រៃលែង **វិសយ** (ដែន) នៃប្រេតទាំងឡាយ មាននិជ្ឈាមតណ្ហិកប្រេតជាដើម ឈ្មោះថា **បេត្តិវិសយ** ប្រេតវិស័យ តាមពិតគួរនឹងពោលថា "**បេតវិសយ**" តែព្រោះលោក ផ្លាស់ **បេត**-ស័ព្ទជា **បេត្តិ** ទើបពោលថា **បេត្តិវិសយ** ។

| ប្រេត | | សភាពរបស់ប្រេត |
|---|---|---|
| ១ | **បរទត្តុបជីវិក**[១] | ប្រេតដែលញុំាងអត្តភាពឱ្យប្រព្រឹត្តទៅបានដោយបុណ្យដែលអ្នកដទៃឧទ្ទិសឱ្យ |
| ២ | **ខុប្បិបាសិក** | ប្រេតដែលមានតែការស្រេកទឹកបៀតបៀន សូម្បីបានទឹកហើយក៏មិនអាចនឹងផឹកបាន |
| ៣ | **និជ្ឈាមតណ្ហិក** | ប្រេតដែលមានសរីរៈត្រូវតណ្ហា គឺសេចក្តីស្រេកឃ្លានដុតពាលជានិច្ច ។ |
| ៤ | **វន្តាសិក** | ប្រេតដែលស៊ីទឹកមាត់ ស្លេស្ម កម្អួត ជាអាហារ ។ |

| | | |
|---|---|---|
| ១ | **អដ្ឋិសង្ខលិក** | ប្រេតដែលឥតមានសាចឈាមឡើយ មានតែរាងឆ្អឹង |
| ២ | **មំសបេសិក** | ប្រេតមានរាងកាយដូចជាចម្រៀកសាច់ |
| ៣ | **មំសបិណ្ឌ** | ប្រេតដែលមានរាងកាយដូចជាដុំសាច់ |
| ៤ | **បុរិសនិច្ឆវិ** | ប្រេតបុរសដែលមានរាងកាយរលោលឥតស្បែក |
| ៥ | **អសិលោម** | ប្រេតដែលមានដាវដោតជាប់នឹងរាងកាយដូចជារោម |
| ៦ | **សត្តិលោម** | ប្រេតដែលមានលំពែងដោតជាប់នឹងរាងកាយដូចជារោម |
| ៧ | **ឧសុលោម** | ប្រេតដែលមានព្រួញដោតជាប់នឹងរាងកាយដូចជារោម |
| ៨ | **សូចិលោម** | ប្រេតដែលមានម្ជុលដោតជាប់នឹងរាងកាយដូចជារោម |
| ៩ | **ទុតិយសូចិលោម** | ប្រេតដែលមានដែកស្រួចចាក់ខ្វាស់នឹងរាងកាយដូចជារោម ទី ២ |
| ១០ | **កុម្ភណ្ឌ** | ប្រេតដែលមានអណ្ឌៈ (ពងស្វាស) ប៉ុនក្អមយ៉ាងធំ |
| ១១ | **គូថខាទក** | ប្រេតដែលលិចចុះទាំងក្បាលទៅក្នុងរណ្តៅលាមក |
| ១២ | **ទុតិយគូថខាទក** | ប្រេតដែលចាប់លាមកដោយដៃទាំងពីរស៊ី |
| ១៣ | **ឥត្ថីនិច្ឆវិ** | ប្រេតស្រីដែលមានរាងកាយរលោលឥតស្បែក |
| ១៤ | **ទុគ្គន្ធ** | ប្រេតដែលមានរាងកាយអាក្រក់គួរខ្ពើមឆ្អើម ក្លិនស្អុយ |
| ១៥ | **ឱកិលិនី** | ប្រេតដែលមានរាងកាយស្រោចដោយរងើកភ្លើង |
| ១៦ | **អសីសកពន្ធ** | ប្រេតឥតក្បាលមានរូបសណ្ឋានដូចសាកអសុភដាច់ក្បាល |
| ១៧ | **ភិក្ខុ** | ប្រេតមានភេទដូចជាភិក្ខុ |
| ១៨ | **ភិក្ខុនី** | ប្រេតមានភេទដូចជាភិក្ខុនី |
| ១៩ | **សិក្ខមានា** | ប្រេតមានភេទដូចជាសិក្ខមានា |
| ២០ | **សាមណេរ** | ប្រេតមានភេទដូចជាសាមណេរ |
| ២១ | **សាមណេរី** | ប្រេតមានភេទដូចជាសាមណេរី |

## អសុរា

**មាន ៣ យ៉ាង** (អសុរកាយ សំដៅយកពួកអសុរដែលជាប្រេតប៉ុណ្ណោះ)

**១.ទេវអសុរា** **(១). វេបចិត្ត** **(២).សុពលិ** **(៣) រាហុ** **(៤). បហារ** **(៥). សម្ពរតី** **(៦). វិនិបាត**

**(១). - (៥).** ព្រោះជាបដិបក្ខជាមួយទេវតាជាន់តាវត្តិង្ស ទើបហៅថា អសុរា, សង្គ្រោះចូលពួកទេវតាជាន់តាវត្តិង្ស (សូម្បីអាស្រ័យនៅបាតភ្នំសិនេរុ) ។

ចំណែកទី (៦). អាស្រ័យនៅក្នុងមនុស្សលោកគ្រប់កន្លែង (មានព្រៃ ភ្នំ ដើមឈើ និងពាងដែលទុកចោល ) ជាបរិវាររបស់កុម្ភណ្ឌទេវតា និងសង្គ្រោះចូលទេវតាជាន់ចាតុម្មហារាជិកា ។

**២.បេត្តិអសុរា** **(១). កាលកញ្ជិកប្រេត** ចាត់ជាពួកអសុរកាយដោយត្រង់
**(២). វេមានិកប្រេត** ពេលថ្ងៃសោយទិព្វសម្បត្តិ ពេលយប់សោយទុក្ខខ្លាំង
**(៣). អាវុធិកប្រេត** មានអាវុធប្រហារគ្នានឹងគ្នា

**៣.និរយអសុរា** អាស្រ័យនៅក្នុងលោកន្តរិកនរក តាំងនៅត្រង់ចន្លោះកណ្តាលនៃចក្រវាឡទាំង ៣ ដែលប្រសព្វគ្នា គោងខ្លួននៅតាមកំផែងចក្រវាឡ ។

[១] ក្នុងប្រេត ៤ ប្រភេទខាងដើមនោះ ព្រះពោធិសត្វទាំងឡាយ រាប់ចាប់តាំងពីទទួលពុទ្ធព្យាករណ៍ជាដើមទៅ រមែងមិនកើតជាប្រេត ៣ ប្រភេទគឺ ខុប្បិបាសិក និជ្ឈាមតណ្ហិក និងកាលញ្ជិកឡើយ បើនឹងកើតក៏នឹងកើតជាបរទត្តុបជីវិកប្រេតតែម្យ៉ាងប៉ុណ្ណោះ ។